long
beach
unified
school
district




សំរាប់ពត៌មានបន្ថែម សូមទាក់ទង
Parent University
562-997-8326

# ថ្នាក់សិក្សាមិនបង់ថ្លៃ

- មានជំនួយមើលកុមារពីអាយុ 4+ ឡើងទៅ
- មានជំនួយបកប្រែភាសា ខ្មែរ
- មានចំណតចតនៅតាម Jackrabbit Lane

**រ្ងល់លង្ខ ចន់ ថ្ងៃអងភ្ន នៅស្ទលង្ខរៀន Poly**
**1600 Atlantic Avenue, Long Beach**
**ម៉ោង 6:00 – 7:30 ល្ងាច**
**សូមធ្វើការចុះឈ្មោះនៅតាម -http://bit.ly/PolyRSVP**

**ថ្ងៃទី១ ខែតុលា – របៀបជ្រើសរើសយកសាលារៀន ហាយស្គូល និង សមត្ថភាពចូលរៀន**
*តើអ្នកដឹងទេថា សិស្សសាលា ហាយស្គូល ទាំងអស់មានសិទ្ធិជ្រើសរើសយកកម្មវិធីទាក់ទងផ្នែកអាជីព និង មហាវិទ្យាល័យ? សូមចូលរួមស្តាប់ការលើកបង្ហាញដោយបុគ្គលិកពីការិយាល័យ High School Choice អំពីសិទ្ធិជ្រើសរើសយកកម្មវិធី សមត្ថភាពចូលរៀន និង ថ្ងៃ ខែ សំខាន់ៗអំពីកម្មវិធី Choice ជាច្រើនលើក ដែលនឹងបើកទទួលជាបន្តនៅពេលខាងមុខនេះ ។*

**ថ្ងៃទី៨ ខែតុលា – សិស្សវ័យជំទង់ និង ថ្នាំញៀនៈ អ្វី ដែលមាតាបិតាត្រូវការដឹងអំពី**
*នេះជាពេលសំរាប់មាតាបិតាពិគ្រោះឆ្លងឆ្លើយអំពីភាពគ្រោះថ្នាក់នៃការប្រើ កញ្ឆា ថ្នាំជក់ ឬ បឺតបង្ហុយផ្សែង និង អ្វីផ្សេងបន្ថែម ។ មាតាបិតានឹងរៀនចំណាំអំពីពេល ដែលសិស្សកំពុងប្រើថ្នាំញៀន លទ្ធផលទាក់ទងសុខភាពផ្លូវចិត្ត និង របៀបអប់រំទៅកាន់កូនរបស់ខ្លួនអំពីថ្នាំញៀន និង សុរា ។ វាគ្មិនៈ Maria Kesler, អ្នកផ្តល់ឪវាទផ្នែកអប់រំថ្នាំញៀននៃកម្មវិធី Long Beach Child and Adolescent Program*

**ថ្ងៃទី១៥ ខែតុលា – ក្រសួងអប់រំ LBUSD និង បណ្ណាល័យសាធារណៈ Long Beach: ជំនួយសំរាប់ភាពជោគជ័យដល់សិស្ស**
*រៀនចំណាំអំពីមធ្យោបាយឃ្លាំមើលភាពលូតលាស់ផ្នែកសិក្សានៃសិស្សរបស់អ្នកតាមការទទួលជំនួយផ្តល់ឡើងដោយក្រសួងអប់រំ LBUSD ។ មានបុគ្គលិកមកពីបណ្ណាល័យ Long Beach Public Library នឹងលើកបង្ហាញពត៌មានជូនមាតាបិតាអំពីឪកាសសំរាប់សិស្ស និង ក្រុមគ្រួសារទទួលជំនួយផ្នែកពន្យល់ ហូមវើក និង កម្មវិធីផ្សេងៗសំរាប់រៀនជាបន្ត ។*

**ថ្ងៃទី២២ ខែតុលា – ការប្រើ បច្ចេកវិជ្ជា នៅតាមបន្ទប់រៀននៃក្រសួងអប់រំ LBUSD**
*តើសិស្សរបស់អ្នកកំពុងប្រើ Google Classroom, Google Docs និង Khan Academy ... ហើយអ្នកកំពុងមិនទាន់យល់ មែនទេ? អ្នកមិនមែនតែម្នាក់ឯងទេ ។ សូមចូលរួមនៅក្នុងកម្មវិធីនេះ ដើម្បីរៀនអំពីអ្វីសិស្សកំពុងប្រើនៅតាមថ្នាក់ និង អ្វី ដែលអ្នកអាចរួមចំណែកជាមួយបាន ។*

**ថ្ងៃទី២៩ ខែតុលា – ការគ្រប់គ្រងនៅពេលសិស្សរបស់អ្នកប្រើ បច្ចេកវិជ្ជា**
*មាតាបិតានឹងរៀនចំណាំអំពីការប្រើ បច្ចេកវិជ្ជា ដែលប៉ះពាល់ដល់សិស្ស ។ សាច់រឿងលើកពិគ្រោះ គឺស្តីអំពី ទំនាក់ទំនងតាមគ្រឿង អេឡិចត្រូនិច ការគំរាមតាមគ្រឿង អេឡិចត្រូនិច និង ជំនួយផ្សេងៗតាមរយៈ អនឡាញ សំរាប់មាតាបិតា ។ សូមអញ្ជើញចូលរួមពិគ្រោះជុំគ្នា!*

**ថ្ងៃទី៥ ខែវិច្ឆិកា – បញ្ហាស្មុគស្មាញក្នុងអារម្មណ៍សំរាប់សិស្សវ័យជំទង់នៅពេលសព្វថ្ងៃ និង អ្វី ដែលមាតាបិតាអាចជួយបាន**
*សូមចូលរួមពិគ្រោះជាមួយយើងខ្ញុំអំពីបញ្ហាសព្វយ៉ាងអំពីភាពស្មុគស្មាញសំរាប់សិស្សរបស់យើង ។ ទទួលការរៀនអំពីមធ្យោបាយសំរាប់ប្រើដោះស្រាយជាមួយក្រុមគ្រួសាររបស់អ្នក ។*

**ថ្ងៃទី១២ ខែវិច្ឆិកា – ឪកាសជ្រើសរើសធ្វើជាបន្ត បន្ទាប់រៀនចប់ពី ហាយស្គូល ផុតទៅ: ការប្រុងប្រៀបរៀននៅមហាវិទ្យាល័យ និង ជ្រើសរើសការងារ**
*រៀនចំណាំអំពីឪកាសជាច្រើនយ៉ាងសំរាប់សិស្សជ្រើសរើសរៀនបន្តនៅតាមមហាវិទ្យាល័យ និង អនុមហាវិទ្យាល័យ ការស្ម័គ្រចូលបំរើកងទ័ព ការរៀនធ្វើជាកូនជាង និង ការរៀនយកមុខវិជ្ជាជំនាញផ្សេងៗ ។ បន្ថែម អ្នកនឹងរៀនអំពីជំនួយស្វែងរកតាមរយៈ អនឡាញ សំរាប់ជួយពន្យល់អំពីរបៀបជ្រើសរើយកអាជីពផ្សេងៗ និង កំរិតសិក្សាតាមសេចក្តីតំរូវ ។*

**ថ្ងៃទី១៩ ខែវិច្ឆិកា – ការរក្សាបីបាច់ក្មេងនៅក្នុងសង្គមមួយដ៏សែនពិបាក**
*សូមអញ្ជើញចូលរួមនៅក្នុងថ្នាក់នេះ ដើម្បីជជែកអំពីការដោះស្រាយបញ្ហាស្មុគស្មាញ អ្វីត្រូវគិតគូរមុនសំរាប់សុខភាពរបស់ខ្លួន និង មធ្យោបាយជួយសិស្សរបស់យើងអោយមានទំនាក់ទំនងល្អ ។*

You Tube

បើអ្នកនឹងមិនអាចចូលរួមក្នុងថ្នាក់បានទេ គឺអ្នកអាចបើកមើលបានជាមួយការបញ្ចាំងផ្សាយផ្ទាល់ភ្លាមៗដោយក្រសួង LBUSD នៅតាម YouTube channel **Link to You Tube**